ឧប សៅ សង្ឃា

# គំនិតនយោបាយហិណ្ឌូ និង ឥទ្ធិពលលើស្រុកខ្មែរ



និមិត្តរូបហិណ្ឌូ

**ការសាកល្បងពិចារណា អំពីគំនិតនយោបាយ**

# មាតិការឿង

គំនិតនយោបាយ នៃហិណ្ឌូ ____ 1
គំនិតនយោបាយ នៃហិណ្ឌូនៅស្រុកខ្មែរ ____ 15

និពន្ធដោយ ឧប សៅ សង្ហា
ខែ មេសា ឆ្នាំ ២០១៨



និមិត្តរូបហិណ្ឌូ

## គំនិតនយោបាយ នៃហិណ្ឌូ

ផ្ទុយពីទស្សនវិជ្ជា នៃសាសនាហិណ្ឌូ ដែលសម្បូរទៅដោយ គំនិតច្រើន ស្មុគ្រស្មាញ និង ល្អិតល្អន់, គំនិតនយោបាយ នៃហិណ្ឌូ ដែលគ្របដណ្ដប់សតវត្ស ពីសម័យកាល វេទ (Védique) ជិតខាងសហស្សវត្សទី២ មុនគ្រិស្តសករាជ រហូតដល់ សម័យកាល នៃការពង្រឹង នៃសាសនាអ៊ីស្លាម នៅសតវត្សទី១៤ ក្រោយគ្រិស្តសករាជ វាមានលក្ខណៈ សាមញ្ញ ប្រហាក់ប្រហែលគ្នា ហើយ ប្តូរតិចតួចណាស់។ គំនិតនោះ វាស្គាល់ នូវការវិវត្តន៍ ដើម្បីឆ្លើយតបនឹងបញ្ហា ទ្រឹស្តី និង ប្រតិបត្តិ កើតឡើងពីព្រឹត្តិការណ៍ ដូចយ៉ាង ការ ផុសចេញ នៃសាសនា ឬ ទស្សនវិជ្ជាផ្សេងៗជាច្រើនទៀត និង វណ្ណៈ ឬ សាជីវកម្ម និង ការឈ្លានពានបរទេសមានហូរ ហែមក។ បើទោះបីជាមាន បំលាស់ប្តូរដូច្នោះ តែប្រភេទ នៃការគិតជាជម្រៅ ការចោទជាបញ្ហា និង របៀបឆ្លើយ ដោះស្រាយ វាស្ថិតនៅស្ទើរតែដដែល។

វិទូនយោបាយហិណ្ឌូ ទុកចក្រវាឡ ជា រដ្ឋ (Rta), សណ្ដាប់ធ្នាប់លោហធាតុ ដែលពុំអាចបំពានបាន, ព្រោះវាជាអំពើ នៃច្បាប់ ដែលជាតំណាង នៃបញ្ញាទិព្វ។ ច្បាប់ទាំងឡាយ នោះ ព្រះអាទិទេព ព្រះអង្គ មិនមែន ជាអ្នកបង្គាប់ និង ជាអ្នកបង្កើតនោះទេ, វាក៏អធម្មជាតិ តែ តាមសារជាតិ

របស់វា វាមានលក្ខណៈសមហេតុផល។ សណ្ដាប់ធ្នាប់ នៃចក្រវាឡ វារក្សាខ្លួនបាន នៅក្នុងវិសាលភាព លុះណាតែអង្គភាពនិមួយៗ វាថែរក្សាទីស្ថានរបស់ខ្លួនរៀងៗខ្លួន និងគោរពច្បាប់។ សង្គមមនុស្ស ជាផ្នែករួមបញ្ចូល នៃចក្រវាឡ ហើយវា បន្តបង្កើត នូវ សណ្ដាប់ធ្នាប់ និង « សច្ចៈភាព » នៃចក្រវាឡបាន លុះណាមនុស្ស រក្សា និង គោរព ធម្ម (dharma)។ ធម្ម, គឺសភាវៈ នៃភាពត្រឹមត្រូវ, គឺជាករណីយកិច្ច។ មនុស្សលោក ខុសពីវត្ថុ មាន ការគិត និង ចេតនា។ វាអាចធ្លាក់ ជាអ្នករងគ្រោះ ដោយប្រទ្បំគំនិត និង មានចំណង់គ្រប់បែបយ៉ាង ហើយ វាវាតពី ធម្ម។ ដូច្នេះ ទណ្ឌកម្ម (Danda) - កម្លាំង និង ទណ្ឌកិច្ច - វាជាច្បាប់ដាក់កំហិត ដើម្បី រក្សាមនុស្សលោក ឱ្យស្ថិតនៅលើផ្លូវត្រង់បាន។

ធម្ម និង ទណ្ឌកម្ម ជាទស្សនៈពីរសំខាន់ នៃគំនិតនយោបាយ នៃហិណ្ឌូ។ ដើម្បីគ្រប់គ្រង សហគមន៍រៀបរយនៅលើដែនដី (territoire) មួយ វាត្រូវចាំបាច់ ប្រើទណ្ឌកម្ម ដើម្បីរក្សា ធម្ម។ ដូច្នោះ អស់វិទូនយោបាយ នាំគ្នាប្រឹក្សា អំពីធម្មជាតិ, មូលដ្ឋាន និង ប្រភព នៃ ធម្ម និង ទណ្ឌកម្ម។ អ្នកខ្លះ បានសរសេរ ធម្មសាស្ត្រា (dharmasastra) ឬ ក្បួន នៃ ធម្ម, អ្នកខ្លះទៀត បានសរ

សេរអំពី ទណ្ឌកម្ម ឬ អធិការសាស្ត្រា (arthasastra)។ វិទូ Kautilya ជាវិទូនយោបាយ ដ៏ចំណានម្នាក់ នៃហិណ្ឌូ លោក ឱ្យអត្ថន័យ អធិការ (artha) ដូចជា ដែនដី និង វិបុលភាព និង អធិការសាស្ត្រា ដូចជាផ្លូវ ដើម្បីទទួលបាន នូវដែនដី និង ធ្វើដែនដីនោះ ឱ្យលូតលាស់ឡើង។ វិធីសាស្ត្រទាំងពីរ នេះ វាបំពេញបន្ថែមគ្នា ប៉ុន្តែបន្តិចម្តងៗ នៅទីបំផុត គេ បានរក្សាទុកតែគំនិត របស់វិទូ Kautilya ថាជា គំនិត នយោបាយច្បាស់លាស់ នៃហិណ្ឌូ។

ទោះបី អស់អ្នកបង្កើតហិណ្ឌូ ទទួលស្គាល់ថា ករណីយកិច្ច មួយចំនួន ដែលមនុស្សត្រូវទទួលខុសត្រូវ ក្នុងតួនាទីជា មនុស្ស តែបន្ទុកនោះ វាប្រែប្រួលទៅតាមបរិបទ។ ករិណីយ កិច្ចមួយចំនួន ត្រូវមនុស្សទទួលខុសត្រូវ ទៅតាមជាតិ កំណើត រៀងខ្លួន នៅក្នុងក្រុមសង្គមពិសេស ឬ វណ្ណៈ (varnadharma) និង អ្នកដទៃទៀត តាមអាយុ នៃជីវិត (ashrama-dharma)។

អ្នកបង្កើតហិណ្ឌូផ្សេងៗទៀត យល់ឃើញថា សង្គម មិន មែនជាការប្រមូលរួម នៃបុគ្គលនោះទេ តែជាសហគមន៍ នៃសហគមន៍ទាំងឡាយ។ សហគមន៍ទាំងនោះ វាជាប់គ្នា ដោយសន្ទាក់ នៅក្នុងវណ្ណៈពិសេសទាំងឡាយ ដែលវណ្ណៈនិមួ យៗ មានមុខងារ សេដ្ឋកិច្ចកំណត់ទុក ហើយ ស្ថិតនៅក្នុង

ស្ថាន របស់ខ្លួន តាមឋានានុក្រម នៃសង្គម។ ធម្ម នៃបុគ្គល វាមានមកពីកំណើតរបស់ខ្លួន។ កំណើតនៅក្នុងវណ្ណៈមួយ មិនមែនជាគ្រោះថ្នាក់ ឬ ចៃដន្យ តែវាជាផល នៃអំពើដែលបានប្រព្រឹត្តពីជាតិមុន ហៅថា កម្ម។ កម្ម វាមានន័យជា អំពើផង និង វាសនាផង។ គ្រប់អំពើ វាបញ្ចេញឱ្យឃើញ និង រចនា នូវកិរិយា នៃភ្នាក់ងារ ដែលវាមានអនុភាពទៅលើ សេរីភាព និង វាសនា ឬ ពៀរវេរា នៃបុគ្គល។ លើសពី វណ្ណៈ នៃខ្លួននេះទៀត បុគ្គល មានមុខងារនៅក្នុងសង្គមជា - បិតា ឬ បុត្រា ស្វាមី ឬ ភរិយា បង ឬ ប្អូន អ្នកជិតខាង - ដែលបង្ខំខ្លួន ឱ្យមានករណីយកិច្ចពិសេស។ បើសិនជាបុគ្គលម្នាក់ៗ ប្រព្រឹត្តិត្រូវតាមទំនងធម្ម នៃខ្លួន វានឹងគ្មាន ការជ្រួលច្របល់នៅក្នុងសង្គមនោះឡើយ។ ដូច្នេះ គេគតត្រូវការ ទណ្ឌកម្ម ឬ រដ្ឋាភិបាលនោះដែរ។ តាមអ្នកបង្កើតហិណ្ឌូជាច្រើន គេយល់ឃើញថាមនុស្សលោក កាលពីព្រេងនាយ រស់នៅនៅក្នុងស្ថានភាពបែបនេះ។ តែដោយហេតុ នៃការខ្វះសីលធម៌ និង ការលោភលន់, អហង្ការ (ahamkar) (ពាក្យសំស្ក្រឹត មានន័យថាឯកត្តភាព ស្រឡាញ់ខ្លួនឯង និង អភិមនៈ) មនុស្សលោកប្រព្រឹត្តិអំពើពុលរលួយ ហើយ នាំគ្នាធ្វើមិនស្គាល់ ធម្ម នៃខ្លួន ដែលនាំឱ្យមាន ការច្របូកច្របល់ នៃវណ្ណៈ -

អវត្តមាន នៃច្បាប់អរិយជាតិ (arajakata) - និង យោគ មគ្គ (yoga) (matsyanyaya ou matsyâsana), ជាច្បាប់កំពូល, ដោយហេតុនេះឯង ដែលត្រីធំ ស៊ីត្រីតូច។ ក្នុងស្ថានភាពបែបនេះឯង ដែលតម្រូវឱ្យមាន រដ្ឋាភិបាល ជាការចាំបាច់ ដើម្បីលំបំបាត់ នូវអំពើទាំងឡាយនោះ។

ទោះបី ស្ទើរតែគ្រប់អ្នកបង្កើតនយោបាយហិណ្ឌូ នាំគ្នាផ្តោត នូវការពិចារណាទៅលើ រាជរដ្ឋាភិបាលហិណ្ឌូ យ៉ាងណាក្តី, តែប្រទេសឥណ្ឌា ជានគរ ធ្លាប់ស្គាល់រួចមកហើយ នូវពហុរបបនយោបាយ - រាជានិយម, អប្បជនាធិបតេយ្យ, សាធារណរដ្ឋ។ ពីដើមធ្លាប់មាន ប្រជាសភា, ក្រុមព្រឹក្សា នៃពលរដ្ឋ, ការបោះឆ្នោត, សាវជីកម្មរៀបរយ។ កណ្ឌមួយ នៅក្នុង ឫគ្វេទ ឬ ឥរុវេទ (Rigveda) សង្ខេបអំពីមនោសញ្ចេតនាដ៏អស្ចារ្យ អំពីគោលគំនិតនៅក្នុងប្រជាសភា : សុំឱ្យបំណងអ្នក មានតែមួយ, សុំឱ្យបេះដូងអ្នក មានឯកច្ឆន្ទ, សុំឱ្យគំនិតអ្នក មានការរួបរួមគ្នា, បើមានដូច្នេះមែន គឺ រវាងអ្នកទាំងឡាយ នឹងមានសាមគ្គីភាពសព្វគ្រប់ជាពុំខាន។ តែជាការចម្លែក របបសាធារណរដ្ឋនៅប្រទេសឥណ្ឌាបុរាណ ពុំមាន កម្រងជាប្រព័ន្ធ នៃការពិចារណានយោបាយ លើកលែងតែ ការពិចារណា របស់វិទូ Kautilya ជាអ្នកទ្រឹស្តីថម នៃអាណាចក្រ Maurya។ ស្នាដៃមួយចំនួនធំ នៃអ្នកបង្កើតហិណ្ឌូ បានបាត់បង់អស់ទៅហើយ, គេរក

ឃើញតែ ស្នាមសំណេរខ្លះ ក្នុងបំណែក នៃពំនោល នៅក្នុង កំណាព្យវិរភាព នៅក្នុង គម្ពីបុរាណ និង នៅក្នុង ចំណេរ នៃរឿងល្ខោន។

ព្រះមហាក្សត្រ តាមគំនិតហិណ្ឌូ ជាអ្នកទទួលបន្ទុក សំរបសំរួល និង ការពារ បថុជ្ជន រស់នៅក្នុសហគមន៍ពិសេស។ យ៉ាងហ្នឹងឯង ព្រះអង្គ ត្រូវអនុវត្ត នូវកិច្ចការរក្សា នៃសណ្តាប់ធ្នាប់ និង ការពារ បូរណភាពដែនដី នៃសហគមន៍ តែព្រះអង្គ ក៏ត្រូវធ្វើឱ្យមានការគោរព ធម្ម, គំនិតត្រឹមត្រូវ, ពាណិជ្ជកម្ម, ការងារ, សុវត្ថិភាព និង សិល្បៈ។ ព្រះមហាក្សត្រ ត្រូវបង្កើតបរិស្ថាន ដែលអាចឱ្យប្រជារាស្ត្រ សំរេចនូវគោលដៅបួនយ៉ាង នៃជីវិត : ធម្ម, ភាពសម្បូណ៌, ការពេញចិត្ត នៃបំណងរបស់ខ្លួន និង ការរំដោះខ្លួនពីវដ្តសង្សារ។ ព្រះមហាក្សត្រ ចូលរួម ក្នុងកិច្ចការ នៃការអភិវឌ្ឍន៍សីលធម៌។ ព្រះមហាក្សត្រ ទ្រង់ញុំាឱ្យផុសប្រាជ្ញា នៃសីលគន្ធ (acharpreraka) និង ព្រះអង្គ ត្រូវតាំងខ្លួនជាអ្នកគោរពចម្បង នៃសីលគន្ធ និង បរិយាកាសសីលធម៌ នៅក្នុងសហគមន៍របស់ព្រះអង្គ។ ចរិយា នៃប្រជារាស្ត្រ វាអាស្រ័យទៅលើកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនផង និង ព្រះមហាក្សត្រផង។ ដូច្នេះ ព្រះមហាក្សត្រ ជាផ្នែកមួយ នៃការទទួលខុសត្រូវលើចរិយារបស់ប្រជារាស្ត្រ និង រួមចំណែក នូវគុណស្រ័យ

និង អគុណស្រ័យ លើឋានសីលធម៌ និង សាសនា របស់ប្រជារាស្ត្រ នៅក្នុងព្រះនគរ។

រាជករណីយកិច្ច នៅក្នុងបញ្ហា នៃការសម្រេច ធម្ម លើកជាសំណួរអំពីប្រភព នៃ ធម្ម។ វិទូនយោបាយហិណ្ឌូភាគច្រើន យល់ឃើញថា គម្ពីរវេទ (Védas), ចរណៈសាស្ត្រា (Smritis) និង ប្រពៃណី (Vyavahara) ជាត្រីប្រភពចម នៃ ធម្ម។ គម្ពីរវេទ បរិយាយអំពី គោលការណ៍សីលធម៌អរូបិយ ហើយមាន ការពិភាក្សាច្បាស់លាស់តិចតួចណាស់ ក៏ដូចគ្នាដែរអំពីករណីយកិច្ច សំរាប់បំពេញ។ ចរណៈសាស្ត្រ ជាក្បួនបំព្រួញយ៉ាងសំខាន់ នៃការអនុវត្តន៍ នៃសេចក្ដីប្រព្រឹត្តិល្អ ពីមុនមក។ ដូច្នេះហើយ គេអាចចាត់ទុកថាប្រពៃណី ជាប្រភពសំខាន់ នៃប្រភព នៃ ធម្ម។

ជនហិណ្ឌូ យល់ព្រមថា គោលការណ៍សីលធម៌ខ្លះ វាមានលក្ខណៈសកល តែទទួច ទៅលើវិរកម្ម នៃសីលធម៌ របស់ជននិករសង្គមមួយ ដែលវារចនា នូវគោលការណ៍សីលធម៌នៃខ្លួន ដោយពេលវេលា និង តំបន់ រស់នៅរបស់ខ្លួន។ ជននិករសង្គមនិមួយៗ រស់នៅក្នុង តំបន់ភូមិសាស្ត្រពិសេស មានការលូតលាស់ នៃសីលធម៌ និង វប្បធម៌ ក្នុងដំណាក់កាលមួយ, សមាជិកទាំងឡាយ ទទួលបាន នូវ « ជាតិធម៌ » (tempérament) និង ការរៀបចំពិសេស ។ល។

ដែលមានជនខ្លះ រស់នៅទីនោះមានការលូតលាស់ នៃរបបជីវិតផ្ទាល់ខ្លួន មានការជំពាក់ចិត្តនឹងរបបនោះ ហើយត្រូវតែគោរពវាទៀតផង។ របនាសម្ព័ន្ធសង្គមឥណ្ឌា មានការចំរើនលូតលាស់ច្រើនក្នុងកំឡុងពេល នៃប្រវត្តិសាស្ត្រ ហើយនៅក្នុងកំឡុងពេលនោះ វាមានកើត វណ្ណៈថ្មី, សាវជីកម្ម, អង្គការសាសនា, ក្រុមប្រឆាំង ឬ គ្មានសសានា (ទមិឡ) តែអ្នកបង្កើតហិណ្ឌូ យកទ្រឹស្តីបុរាណ នៃ ធម្ម មកដោះស្រាយ នូវបញ្ហានេះ ដោយ ទទួលស្គាល់ សិទ្ធិអ្នកទាំងនោះ ធ្វើកិច្ចការ ទៅតាមទំនៀមស្រុករបស់គេរៀងៗខ្លួន។ ព្រះមហាក្សត្រ ក៏គ្មានសិទ្ធិនឹងធ្វើអន្តរាគមន៏ ក្នុងកិច្ចការរបស់គេ លើកលែងតែសិទ្ធិនោះវាមានភាពមិនច្បាស់លាស់ ឬ ផ្ទុយពីប្រយោជន៏រួម។ ដូច្នេះ ព្រះមហាក្សត្រ ទ្រង់គ្រប់គ្រង លើសណ្តាប់ធ្នាប់សង្គមខុសៗគ្នា និង វិមជ្ឈការខ្លាំងណាស់។ រាជអំណាច និង រាជអធិការ របស់ព្រះអង្គ វាមានកំណត់ ទៅតាមស្វ័យភាព របស់អង្គភាពសាវជីកម្មនិមួយៗ ដែលគ្មាននរណាអាចនឹងបំពានវាបានជាដាច់ខាត។ ដូច្នេះ ទស្សនៈ អត្តាវសនិយម (despotisme) នៃបូព៌ាប្រទេស មិនអាចយកមកអនុវត្ត បានឡើយ នៅក្នុងប្រទេសឥណ្ឌាបុរាណ។

អ្នកបង្កើត ហិណ្ឌូ ជាច្រើន គេយល់ព្រមគ្នា លើរចនាសម្ព័ន្ធផង និង របៀប នៃសកម្មភាព របស់រដ្ឋាភិបាលផង។

ជនាធិប ឬ អ្នកគ្រប់គ្រងរក្សាប្រជាជន (le politique) ត្រូវមានអង្គការ ឬ វត្ថុ៧យ៉ាង - ព្រះមហាក្សត្រ, រដ្ឋមន្ត្រី, សហគមន៍ដែនដី, បន្ទាយ ឬ បាការដ្ឋាន, ទ្រព្យសម្បត្តិ, កងទ័ព និង សម្ពន្ធមិត្ត។ ការរៀបចំ នៃអង្គការនិមួយៗ ត្រូវបានគេពិពណ៌នា បែបយ៉ាងពិស្តា។ គេអាចរក្សាអំណាចបាន តាម ការបញ្ចុះបញ្ចូល, សិថិលភាព (concession), ថៃថ្នូរ ឬ កម្លាំង។ អ្នកបង្កើត នយោបាយហិណ្ឌូ ស្ទើរតែទាំងអស់ ទទូចលើការចាំបាច់ ត្រូវមានពួកអ្នករាជការ ឬ មន្ត្រី មានសមត្ថកិច្ច និង ប្រសិទ្ធិភាព នូវ បណ្ដាញចារកិច្ច។ ព្រះមហាក្សត្រ មានសិទ្ធិបង្គារ សហគមន៍ - តាមធម្មកំពូល របស់ព្រះអង្គ និងទៅតាមបរិបទ នៃស្ថានការណ៍ ដែលព្រះអង្គជួបប្រទះ។ នៅក្នុងរឿង មហាភារតយុទ្ធ (Mohabharata), ព្រះគ្រឹស្នា (Khrishna) ព្រះអង្គខ្លួនឯងនៅពេលខ្លះ ទ្រង់ កុហក។ ការណ៍នេះបញ្ជាក់ឱ្យឃើញថា សូម្បី ព្រះអាទិទេព ក៏ត្រូវយកអំពើអសីលធម៌ មកប្រើ នៅពេលដែលខ្លួន ជួបប្រទះនឹង ការតម្រូវចាំបាច់ នៃបញ្ហានយោបាយ។

អ្នកបង្កើត នយោបាយ ហិណ្ឌូ ទាំងឡាយ យល់ស្របគ្នាផងដែរ លើទស្សនៈមួយចំនួន ដូចយ៉ាងការគោរពនយោបាយទណ្ឌកម្ម និង ការយកពន្ធដារ និង ត្រូវតែមានភារៈចំពោះព្រះមហាក្សត្រ ព្រោះព្រះអង្គ ជាអ្នកថែរក្សា សណ្ដាប់

ផ្ដាប់សង្គម និង អាចឱ្យប្រជារាស្ត្រ រស់នៅ ប្រកបដោយវិន័យ និង សីលធម៌។ ព្រះអង្គ ជាព្រះមហាក្សត្រពេញសិទ្ធិតាមរាជអភិសេក តែរាជ្យភង្គ (អ្នកដណ្ដើមរាជ្យ) អាចដណ្ដើមរាជអំណាចបាន ហើយ អាចប្រជារាស្ត្រគោរពខ្លួនបាន បើអ្នកនោះ ប្រតិបត្តិត្រឹមត្រូវតាម ទសពិធរាជធម៌។ ក្នុងករណី មានការសង្កត់សង្កិន ពីសំណាក់ព្រះមហាក្សត្រ, អ្នកបង្កើត ហិណ្ឌូ ខ្លះ យល់ឃើញថា ប្រជារាស្ត្រ ត្រូវនៅតែបន្តគោរពព្រះអង្គជានិច្ច, អ្នកខ្លុះទៀត យល់ឃើញថា រាស្ត្រត្រូវនាំគ្នា និរទេសខ្លួន, អ្នកខ្លះទៀត យល់ឃើញថា ប្រជារាស្ត្រ ត្រូវរំលំព្រះមហាក្សត្រ ឬ ធ្វើឃាតអ្នកផ្ដាច់ការនោះ តែម្ដង។

អ្នកបង្កើត ហិណ្ឌូ ជាច្រើន អភិប្រាយ អំពីទ្រឹស្ដីមុខងារ នៃការយកពន្ធដារ : ពន្ធដារ ជាតម្លៃ នៃរាជកិច្ចការពារ ដែលប្រជារាស្ត្រត្រូវតែបង់ពន្ធ ដោយប្ដូរយក នូវការធានា នៃសុវត្ថិភាព និង ការពារទ្រព្យសម្បត្តិរបស់ខ្លួន។ បើព្រះមហាក្សត្រ មិនអាចបំពេញរាជកិច្ចការនោះបាន ព្រះអង្គ ត្រូវតែសងត្រឡប់វិញ។ ទណ្ឌកម្ម មានគោលដៅ ៥យ៉ាង : រក្សាសណ្ដាប់ធ្នាប់សង្គម, ទុកជាមេរៀនចំពោះអ្នកដទៃ, ឃាត់បុគ្គលទាំងឡាយកុំឱ្យធ្វើអំពើអកុសល, បង្ហាញ នូវសេចក្ដីប្ដេជ្ញា មិនអត់ធ្មត់ នៅចំពោះមុខអំពើ ដែលនាំឱ្យមានកើត អកុសលដល់សង្គម និង នៅទីបញ្ចប់ ធ្វើបន្សុទ្ធកម្ម

ដល់ជនឧក្រិដ្ឋ ទុកជាកម្មវិបាក នៃអំពើឧក្រិដ្ឋរបស់ខ្លួន។ ធម្មជាតិ និង សេចក្តីតឹងរ៉ឹង នៃទណ្ឌកម្ម វាត្រូវតែប្រែប្រួលតាមលក្ខន្តិកៈសង្គម របស់អ្នកទោស។ វណ្ណៈខ្ពង់ខ្ពស់ ត្រូវទទួលត្រឹមតែលហុទោស ហើយ ត្រូវរួចផុតពីទណ្ឌកម្មសារីរិក។

## ពុទ្ធសាសនា

ពុទ្ធសាសានា បង្ហាញ នូវដំណាក់ការដ៏សំខាន់មួយ អំពីសេចក្តីអធិប្បាយ នៃគំនិតនយោបាយហិណ្ឌូ ព្រោះពុទ្ធសាសនា បដិសេធ នូវប្រព័ន្ធ នៃវណ្ណៈ ដែលនាំបង្កើត នូវវត្តអារាម និង ផ្តល់ដល់ប្រទេសឥណ្ឌា ជាលើកដំបូង នូវការពិសោធមួយ នៃដំបន់រៀបរយ តែគ្មានទេវវិជ្ជា។ នៅទីនោះ ស្ត្រី ត្រូវបានគេទុកជា បុគ្គលសង្គមពេញសិទ្ធិ និង វណ្ណៈទាប ដែលគេមិនសូវយកចិត្តទុកដាក់ ដូចយ៉ាង ពួកសិប្បករ និង ពាណិជ្ជករ (វណ្ណៈវេស្សៈ) ជាអ្នកប្រកបមុខងារសំរាប់ប្រជាប្រយោជន៏។ តែ ពុទ្ធសាសនា ទទួលស្គាល់ ទស្សនៈហិណ្ឌូ ស្តីពីកាតព្វកិច្ចជាមូលដ្ឋាន របស់ព្រះមហាក្សត្រ គឺការរក្សា ធម្ម តែបដិសេធ នូវអត្តវត្ថុ នៃធម្ម គឺវណ្ណៈ។ ដូច្នេះ ព្រះមហាក្សត្រ តទៅមុខ ជាអ្នកកំណត់ដោយច្បាស់លាស់ នៃពុទ្ធធម្ម (dhamma) ដោយខ្លួនឯង។ ពុទ្ធសាសនា ជាលើកដំបូង បានបញ្ជូលគំនិតនីតិបញ្ញាតិ នៅ

ក្នុងប្រវត្តិសាស្ត្រ នៃគំនិតហិណ្ឌូ គឺទុក ច្បាប់ជា កិច្ច នៃឆន្ទៈ ហើយ អំណាច នៃច្បាប់ វាកើតមានឡើងពីគោលការណ៍ឧបាសក។ ពុទ្ធសាសនា បានបង្កើតផងដែរ នូវទ្រឹស្ដីកិច្ចសន្យាស្មើរតែទាំងអស់ ស្ដីពី របៀបធ្វើការ របស់រដ្ឋាភិបាល ហើយប្រកាសថា អាជ្ញាធរនយោបាយ កើតចេញពីប្រជាពលរដ្ឋ។ ប៉ុន្តែ ឥទ្ធិពល នៃពុទ្ធសាសនា មានកំរិតតិចណាស់នៅក្នុងសង្គមឥណ្ឌា។ ទោះបើ ទស្សនវិជ្ជា នៃពុទ្ធសាសនា គេទុកជាទស្សនៈបដិវត្តន៍ក្តី តែទ្រឹស្ដីនយោបាយវាគ្មានលក្ខណៈដូចយ៉ាងនោះឡើយ។ ពុទ្ធសាសនា ទទួលគោលលទ្ធិសំខាន់ៗ នៃគំនិតហិណ្ឌូ ដូចយ៉ាង ជីវិត ជាទុក្ខ, តណ្ហា ជាការប្រាថ្នាអាក្រក់, កម្មពី អតិតជាតិ នៃមនុស្សម្នាក់ៗ កំណត់ នូវចរិករបស់ខ្លួនក្នុងជីវិតបច្ចុប្បន្នកាល និង ករណីយកិច្ចខ្ពង់ខ្ពស់ នៃរដ្ឋាភិបាល គឺរក្សា ធម្ម។ ពុទ្ធសាសនា ពុំបានដោះសាយ នូវគោលការណ៍ នៃសមភាពដល់អ្នកក្រ និង វណ្ណៈសូទ្រៈ និង ជំទាស់ អំពីការបម្រុងទុកនៃអំណាចនយោបាយ សំរាប់តែវណ្ណៈខ្ពស់ ដូចយ៉ាង វណ្ណៈក្សត្រិយ: និង យកអ្វីមួយមកជំនួស ដល់ការគ្រោបសង្កត់ពីវណ្ណៈមួយ ទៅលើវណ្ណៈមួយទៀត ដូចយ៉ាង វណ្ណៈ ព្រាហ្មណៈ និង ក្សត្រិយៈ ទៅលើ វណ្ណៈវេស្សៈ និង សូទ្រៈ។ ពុទ្ធសាសនា បានរួមចំណែកធ្វើការរៀបចំឡើងវិញ តែមិន

បំផ្លិចបំផ្លាញ នូវគោលគំនិតនយោបាយហិណ្ឌូ អំពីទម្រង់បុរាណ នៃការគ្រោបសង្កត់នយោបាយនោះទេ។

## លក្ខណៈសំខាន់ នៃគំនិតនយោបាយហិណ្ឌូ

**លក្ខណៈទី១** : មូលដ្ឋាន ជាប្រពៃណី គឺ ការពិពណ៌នា និង ការអប់រំ, តែវាខ្វះ នូវទស្សនវិស័យវិភាគ, ទស្សនវិស័យទ្រឹស្តី និង ទស្សនវិស័យរំពឹងទុក។ ហេតុនេះឯង បានជាវាមិនបានផ្តល់ឱ្យកើនឡើង នូវការនិពន្ធដ៏ប្រសើរ នៅក្នុងវិស័យ នៃទស្សវិជ្ជានយោបាយ ដូចទស្សនវិជ្ជាហិណ្ឌូ ក្នុងវិស័យតក្កវិជ្ជា និង ទស្សនវិជ្ជា ខាងការសិក្សាខាងប្រវត្តិសាស្ត្រវិធានការ និង គោលការណ៍ នៃវិទ្យាសាស្ត្រ (épistéologie)។

**លក្ខណៈទី២** : មូលដ្ឋាន គឺ អភិរក្សនិយម និង ការសរសើរ ហើយមិនអនុញ្ញាតិ នូវគំនិតរិះគន់។ លើកលែង តែពុទ្ធសាសនា, អ្នកបង្កើតហិណ្ឌូទាំងឡាយ មិនមានគំនិតសើរើលើ អត្តភាព នៃប្រព័ន្ធវណ្ណៈ ទុកជាមូលដ្ឋានដាច់ខាត នៃសណ្តាប់ធ្នាប់សង្គម។

**លក្ខណៈទី៣** : មើលឃើញថា មនុស្សម្នាក់ៗ ជាសមាជិកនៅក្នុងក្រុមសង្គមផ្សេងៗគ្នា ហើយទទួលបន្ទុករៀងៗខ្លួននៅក្នុងតួនាទីសង្គមមួយចំនួន។ បែបដូច្នេះ វាសង្កត់ទៅលើការណើយកិច្ច ជាង សិទ្ធិ របស់មនុស្ស។

**លក្ខណៈទី៤** : ដោយសារតែធ្វើការសន្និដ្ឋានដំបូង នៅក្នុងទ្រឹស្តី, ហិណ្ឌូ ទុក សច្ចៈភាព ជាពហុចនៈមូលដ្ឋាន។ ក្នុងគំនិតនេះ នាំឱ្យមានការអនុគ្រោះ ដល់នានាភាព (diversité) នៃជំនឿ និង ការអនុវត្តន៏។ តែការអនុគ្រោះនោះ វាខាឃាំង មិនអាចបង្កើត នូវគោលការណ៍ទូទៅបានដែរ ដែលជាគោលការណ៍ សំរាប់វាយតម្លៃ និង ធ្វើការរិះគន់ លើជំនឿទាំងឡាយ។

នៅទីបញ្ចប់ ដោយបានផ្តល់ នូវឥទ្ធិពល នៃប្រពៃណី អ្នកបង្កើត ហិណ្ឌូ មិនចាំបាច់ត្រូវការល្បងគិតបង្កើតឱ្យមានគំនិតនីតិបញ្ញាតិ ហើយ យល់ឃើញថា អំណាចដឹកនាំ តាមធម្មជាតិ វាជា លំដាប់គុលាការ ជាង លំដាប់នីតិបញ្ញាតិ។ ដូច្នេះ ពួកគេ មិនបានបង្កើត នូវគំនិត ដូចយ៉ាងអធិបតេយ្យភាព, ឆន្ទៈ, ភាពសមហេតុផលនយោបាយ, ឯកភាព នៃប្រព័ន្ធច្បាប់ នៅក្នុងប្រទេស និង ទុករដ្ឋាភិបាល ជាភ្នាក់ងារ នៃបំលាស់ប្តូរសង្គម។ តែថាគំនិតទាំងឡាយនេះឯង វាជាកត្តា មានតួនាទីមជ្ឈឹម ក្នុងការធ្វើអភិវឌ្ឍន៏ នៃរដ្ឋទំនើប នៅទ្វីបអឺរ៉ុប។

# គំនិតនយោបាយ នៃហិណ្ឌូនៅស្រុកខ្មែរ



អង្គរវត្ត

អារ្យធម៌ខ្មែរ ទទួលឥទ្ធិពលពីហិណ្ឌូ។ ព្រះបាទ ហ៊ុន ទៀន (ដើមសតវត្សទី៣ នៃគ្រិស្តសករាជ) ជាភ្នាក់ងារ នៃអារិយធម៌ឥណ្ឌា។ ព្រះអង្គ ជាអ្នកយកសាសនាព្រាហ្មណ៍ មកអនុវត្តមុនដំបូងគេបង្អស់នៅស្រុកខ្មែរ តែព្រះអង្គ មិនបំផ្លិចបំផ្លាញជំនឿអាយ ស្របតាម គោលការណ៍ នៃនានាភាព នៃហិណ្ឌូ។ ដូច្នេះនៅពេលនោះ វាគ្មានការបង្ខំ ឱ្យមានការបែងចែកវណ្ណៈហិណ្ឌូ នៅក្នុងសង្គមខ្មែរបុរាណនោះឡើយ។ គេអាចទុក រយៈពេល សន្តតិវង្ស នៃព្រះបាទ ហ៊ុន ទៀន ជារយៈពេល សម្របសម្រួល នៃព្រហ្មញ្ញសាសនា នៅស្រុកខ្មែរ ក្នុងគោលគំនិតសន្តិភាពសង្គម។ ព្រហ្មញ្ញសាសនា វិវឌ្ឍ ដោយស្ងប់ស្ងាត់ ហើយសម្របខ្លួនច្រើន ទៅតាមប្រពៃណីអ្នកស្រុកដើម តែរក្សាគោលការណ៍ធំៗ របស់ខ្លួន តួយ៉ាង ឧត្តមភាព នៃរាជានិយម និង អំណាចដឹកនាំ ទុកជា លំដាប់តុលាការ ជាង លំដាប់នីតិបញ្ញត្តិ។ ការវិវឌ្ឍបែបនេះ អនុគ្រោះ នូវការវិវឌ្ឍន៍ ដោយស្របគ្នា នៃពុទ្ធសាសនាមហាយាន នៅក្នុងមជ្ឈដ្ឋានបថុជ្ជន។

មួយវិញទៀត ព្រះបាទ ជ័យវរ្មនទី២ (៨០២-៨៥០) ជាអ្នកបង្កើត លទ្ធិទេវរាជ ក្នុងគោលដៅសំខាន់ គឺ បង្រួបបង្រួមជាតិ : ប្រជាជាតិតែមួយ លទ្ធិដឹកនាំតែមួយ តែព្រះអង្គក៏

មិនហាមដាច់ខាតមិនឱ្យរាស្ត្រម្នាក់ៗ មានជំនឿផ្ទាល់ខ្លួននោះឡើយ តែត្រូវតែទទួលស្គាល់លទ្ធិទេវរាជ ជាគោលលទ្ធិជាតិ។ ដូច្នេះ លទ្ធិទេវរាជ វាគ្រាន់តែជា ឧបករណ៍នយោបាយ សំរាប់រក្សាឯកភាពជាតិ និង បង្កើត លក្ខណៈសម្បត្តិពិសេស របស់ព្រះមហាក្សត្រ គឺ អវតា នៃអាទិទេពលើដែនដី ផ្គត់ផ្គង់ដោយសិទ្ធិទិព្វពិតប្រាកដ។ ការបង្កើតលទ្ធិទេវរាជនៅស្រុកខ្មែរ គេអាចទុកជាឈានដ៏ធំ នៃព្រហ្មញ្ញសាសនា នាំតម្កើងតួនាទី នៃវណ្ណៈព្រាហ្មណ៍ នៅក្នុង រាជានិយមខ្មែរ។ ពួកបុរោហិត នៅក្នុងបរមរាជវាំង ប្រែក្លាយជារួមពួក (associé) នៃព្រះរាជាតែម្តង និង វត្តុជាតុបញ្ឈូលនៃប្រព័ន្ធដឹកនាំ ព្រោះខ្លួនជានិរសាផ្ទាល់ រវាង ទិព្វលោក និង លោកិយ។ គ្មានព្រះបុរោហិត គឺគ្មានសម្ព័ន្ធ រវាងព្រះមហាក្សត្រ ជាមួយនឹង ទិព្វលោក។ ព្រះមហាក្សត្រពេញសិទ្ធិ មិនគ្រាន់តែបានធ្វើរាជអភិសេក តាមព្រះរាជប្រពៃណី គឺត្រូវប្រារព្ធធ្វើពិធីថ្មីមួយទៀត ហៅថា « ពិធីទេវរាជ » ក្នុងបំណងធ្វើឱ្យព្រះមហាក្សត្រ មានឋានៈជាចក្រវាតីន (ស្តេចចក្រវាឡ)។ ពីធីថ្មីនេះអាចធ្វើបាន ហើយ ពេញសិទ្ធិ លុះត្រាតែមាន ជាចាំបាច់ ព្រាហ្មណ៍ ចេះមន្តអាគមពិសេស តាមគម្ពី វិនាសិខ ជាអ្នកពិធីការ។ ព្រះបាទជ័យវរ្មនទី២ ទាំងព្រហ្មណ៍ ឈ្មោះ ហិរណ្យ (ព្រាហ្មណ៍ ជាអ្នកពិធីការ) បានធ្វើសច្ចាថា អំណេះតទៅ មានតែសមាជិកគ្រួសារ

នៃព្រាហ្មណ៍ សិវកៃវល្យ (ព្រាហ្មណ៍ ដែលមានគំនិតបង្កើតលទ្ធិទេវរាជដំបូង ហើយជា ព្រះបុរោហិត ឬ ព្រះរាជគ្រូ នៃព្រះបាទជ័យវរ្ម័នទី២) ទេ ដែលអាចប្រារព្ធធ្វើទេវរាជនេះបាន។ អបរិយាប័ន្នភាព (ការមានដាច់មុខ) នេះឯង បញ្ជាក់ច្បាស់អំពី ចំណងពិសេស រវាង វណ្ណៈព្រាហ្មណៈ និង ក្សត្រិយៈ និង បូរណកម្ម នៃវណ្ណៈព្រាហ្មណៈ នៅក្នុងរាជានិយម នៅស្រុកខ្មែរ។

ចំណែកព្រះបាទ ជ័យវរ្ម័នទី៧ (១១៨១-១២១៩) វិញ ព្រះអង្គអនុគ្រោះ ពុទ្ធសាសនា នៅក្នុងរាជានិយមខ្មែរ តែមិនបោះបង់ចោល គំនិតនយោបាយ និង រចនាសម្ព័ន្ធ ហិណ្ឌូនៅក្នុងប្រព័ន្ធដឹកនាំ នោះឡើយ។ ចំណុចនេះឯង ដែលគេអាចទុកជា ការបំបែក ជំនឿសាសនា ពីប្រព័ន្ធដឹកនាំ។ ដូច្នេះ ពួកមន្ត្រីខ្មែរ គាត់អាច ជាពុទ្ធសាសនិក ជាព្រាហ្មណ៍សាសនិក ទៅតាមជម្រើសរៀងៗខ្លួន។ គំនិតនេះ ខ្មែរតែងតែទុកជាគំនិតបដិវត្តន៍ របស់ព្រះបាទជ័យវរ្ម័នទី៧, តាមការពិត ព្រះអង្គគ្រាន់តែយក គោលការណ៍មូលដ្ឋាន នៃហិណ្ឌូ មកអនុវត្តគឺ « នានាភាព » ក្នុងគោលដៅរក សិទ្ធិពលសង្គម តែប៉ុណ្ណោះ។ តែផ្ទុយទៅវិញ ការអនុវត្តន៍បែបនេះ នាំបង្កើត ជម្លោះកំបាំង នៅក្នុងមជ្ឈដ្ឋាន នៃអ្នកដឹកនាំ (ក្រុមមន្ត្រី) ដែលចាប់ចេញរូបបន្តិចម្តងៗ មានបន្តក្រោយពីទីចប់ នៃរាជ្យព្រះបាទជ័យវរ្ម័នទី៧។ ដូច្នេះ

ឯង ទីចប់ នៃរាជ្យព្រះបាទជ័យវរ្មនទី៧ វាមានអាថ៌កំបាំងណាស់ រហូតគេមិនដឹងកាលបរិច្ឆេទពិតប្រាកដផង ហើយស្ដេច ដែលបន្តសោយរាជ្យ ពីព្រះបាទជ័យវរ្មនទី៧ ទ្រង់គ្មានជាប់ខ្សែញាតិវង្សអ្វីសោះនឹងព្រះអង្គ។ ការណ៍ហ្នឹង វាអាចទុកជា ការចម្លែកមួយដែរ បើប្រៀបធៀបទៅនឹងកេរ៍ឈ្មោះល្បីល្បាញ របស់ព្រះបាទជ័យវរ្មនទី៧ គឺថា ព្រះអង្គគួរបង្កើតបាន នូវសន្តតិវង្សមួយ ដែលមានរយៈពេលយូរបាន។

នៅស្រុកខ្មែរ ការវិវត្តន៍ នៃហិណ្ឌូ រៀបរាប់ខាងលើនេះ វាបង្ហាញ នូវលក្ខណៈថាវរភាព នៃមូលដ្ឋានហិណ្ឌូ តែរាជានិយមខ្មែរ គេយកមកកែសម្រួលខ្លះ ក្នុងការប្រតិបត្តិ ឱ្យស្របទៅនឹងបរិបទខ្មែរ, តួយ៉ាង ទុកវណ្ណៈក្សត្រិយៈ ជាអំណាចមជ្ឈឹម និង ដាច់មុខ។ អត្ថិភាព នៃវណ្ណៈហិណ្ឌូផ្សេងៗទៀត ជាអត្ថិភាពបន្ទាប់បន្សំ លើកលែងតែ ពួកព្រាហ្មណ៍បុរោហិត ដែលមានឥទ្ធិពល នៅក្នុងព្រះបរមរាជវាំង។ សង្គមខ្មែរ ជាសង្គម មានជាតិសាសន៍សភាគ ដូច្នេះ ការបំបែកប្រជារាស្ត្រ ជាវណ្ណៈ ជាផលវិបាក សំរាប់ការគ្រប់គ្រង ព្រោះ វានាំបង្កើត ភាពតានតឹងនៅក្នុងសង្គម។ ដូច្នេះ តាំងពីដើមដំបូងមក តួយ៉ាង ព្រះបាទ ហ៊ុន ទៀន ក្ដី ព្រះបាទជ័យវរ្មនទី២ ក្ដី និង ព្រះបាទជ័យវរ្មនទី៧ ក្ដី ព្រះអង្គទាំងឡាយ តែងតែយក គោលការណ៍មូលដ្ឋានហិណ្ឌូ

មកអនុវត្ត គឺ នានាភាព និង ការសម្របសម្រួល គំនិតនយោបាយហិណ្ឌូ ជាមួយនឹងវប្បធម៌អាយ ដែលជាគន្លឹះជោគជ័យ នៃការកើត អារ្យធម៌អង្គរ ដែលជាអារ្យធម៌ល្បីល្បាញមួយនៅក្នុងពិភពលោក។ ភាពបំព្រួញ គោលការណ៍ទាំងពីរនេះឯង (schématisme binaire) នេះ អាចទុកជាស្នាដៃល្អ របស់ស្តេចខ្មែរភាគច្រើន នៅសម័យមហានគរ ដែលតែងតែស្វែងរក នូវការចូលរួម នៃប្រជារាស្ត្រ ក្នុងនយោបាយជាតិ ដែលនាំឱ្យប្រជាជាតិខ្មែរ ស្គាល់ នូវភាពរុងរឿងពិសេស ហើយទុកស្នាម ឆព្វណ្ណរង្សី នេះ រហូតមកដល់បច្ចុប្បន្នកាល។ តែសព្វថ្ងៃ កិត្តិគុណ នេះ វាគ្រាន់តែជាអតីតកាល នៃការស្រមើស្រមៃ តែប៉ុណ្ណោះ សំរាប់ប្រជាពលរដ្ឋខ្មែរ។ សួរថា តើអ្នកណា ដែលមានកំហុស ?